វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ការឃ្លាំមើលការអភិវឌ្ឍន៍ នៅកម្ពុជា







## មាតិកា


វិមជ្ឈការ និងវិសហមជ្ឈការគឺជាចរឹតលក្ខណៈចម្បងនៃការអនុវត្តសារាចរលេខ ០៣.................១

បំណុលក្រៅប្រទេសរបស់កម្ពុជា: ជាបញ្ហាគួរឲ្យបារម្ភមួយឬទេ?
.........................................៧

ការគ្រប់គ្រងប្រទេសកម្ពុជា: ដំណាក់កាលខាងមុខនៃកំណើន
.......................................១៧


ឆ្នាំទី៧ ចេញផ្សាយលើកទី ២ - ខែធ្នូ ឆ្នាំ ២០១១

**ការឃ្លាំមើលការអភិវឌ្ឍន៍នៅកម្ពុជា**

បោះពុម្ពនៅ ខែធ្នូ ឆ្នាំ២០១១
ការបោះពុម្ពផ្សាយនេះ បានទទួលការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយនៃ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

**បញ្ជាក់៖**
មតិយោបល់ និងសេចក្តីសន្និដ្ឋានទាំងឡាយគឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ដោយមិន
ឆ្លុះបញ្ចាំងនូវទស្សនៈ និងគោលជំហររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ទាំងអស់ឡើយ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# បុព្វកថា

ការបោះពុម្ពទស្សនាវដ្ដីឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា ផលិតដោយគម្រោងគោលនយោបាយអភិវឌ្ឍន៍នៃ វេទិកានៃ អង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា។ ទស្សនាវដ្ដីនេះមានបំណងគូសបញ្ជាក់នូវទស្សនរបស់អង្គការសង្គម ស៊ីវិលទៅលើ៖ ១) គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ២) ការអនុវត្តនូវគោលនយោបាយទាំងនោះ ៣) ការចែករំលែកព័ត៌មាន និង ៤ ) ជំរុញការពិភាក្សាក្នុងចំណោមសាធារណជន និស្សិត អង្គការសង្គមស៊ីវិល អ្នកធ្វើគោលនយោបាយ និងដៃគូអភិវឌ្ឍន៍ ថាតើការអនុវត្តនូវកម្មវិធី និង គោលនយោបាយទាំងឡាយជួយដល់ការកាត់បន្ថយភាពក្រីក្រ និង កិច្ចអភិវឌ្ឍន៍នៅកម្ពុជា យ៉ាងដូចម្ដេច។

ប្រធានបទនៅក្នុងទស្សនាវដ្ដីការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជានេះ ត្រូវបានសរសេរ និងលើកឡើងដោយ៖ លោក អាប់ឌុល វ៉ាស្ស៊ីដ ខាទ្រី ទីប្រឹក្សា (អង្គការដៃគូរៀបចំការអភិវឌ្ឍន៍សហគមន៍ "CMDP") លោក ជា គីមសុង ប្រធានកម្មវិធី បញ្ហាអភិវឌ្ឍន៍ (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ) លោក ហេង ឌីណា (និស្សិតមហាវិទ្យាល័យក្រាហ្វដផ្នែកសេដ្ឋកិច្ចនិងរដ្ឋាភិបាលនៃសាកលវិទ្យាល័យជាតិអូស្រ្ដាលី )។

សូមថ្លែងអំណរគុណផងដែរដល់ លោក ខាំ វ៉ាន់ដា អ្នកសម្របសម្រួលគម្រោងគោលនយោបាយអភិវឌ្ឍន៍ និង លោក ជា គីមសុង ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ ក្នុងការសម្របសម្រួលដំណើរការផលិត និង លោក ភួន យូ មន្រ្ដីទំនាក់ទំនង និងការផ្សព្វផ្សាយនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ក្នុងការខិតខំប្រឹងប្រែងរៀបចំរចនាការបោះពុម្ពទស្សនាវដ្ដី នេះ។

ការបោះពុម្ពនេះនឹងមិនអាចលេចជារូបរាងបាននោះទេបើគ្មានការជួយឧបត្ថមពីម្ចាស់ជំនួយនៃវេទិកានៃអង្គការមិនមែន រដ្ឋាភិបាល ស្ដីពីកម្ពុជាសម្រាប់ការផលិតទៀងទាត់នូវទស្សនវដ្ដីការឃ្លាំមើល ការអភិវឌ្ឍន៍នៅកម្ពុជា។

យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិយោបល់បែបស្ថាបនាទាំងឡាយដើម្បីកែលម្អការបោះពុម្ពផ្សាយទស្សនាវដ្ដីឃ្លាំមើល ការអភិវឌ្ឍន៍នៅលេខក្រោយៗទៀត។

**លោក ឈិត សំអាត**

**នាយកប្រតិបត្តិ**
**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា**

# វិមជ្ឈការ និងវិសហមជ្ឈការគឺជាចរិតលក្ខណៈចម្បងនៃការអនុវត្តសារាចរលេខ ០៣

## ១. សាវតារ– កិច្ចប្រឹងប្រែងដោះស្រាយបញ្ហាលំនៅឋានក្រៅប្រព័ន្ធនៅខេត្តបាត់ដំបង

ក្រុងបាត់ដំបង គឺជាទីក្រុងធំបំផុតទីពីរនៃប្រទេសកម្ពុជា ដែលមានប្រជាជនសរុបប្រហែល ១៥០.០០០ នាក់។ យោងតាម ការអង្កេតមួយដែលបានធ្វើក្នុងឆ្នាំ ២០០៩ គេឃើញមានលំនៅឋានមិនរៀបរយចំនួន ៦៤ កន្លែងដែលមានគ្រួសារចំនួន២២០០.និង ប្រជាជនចំនួន ១០ .០០០នាក់។ នៅក្នុងកិច្ចដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្រុងបាត់ដំបង ក្នុងឆ្នាំ២០០៥ (ដែលត្រូវបានឧបត្ថម្ភដោយអង្គការ GIZ ដែលកាលពីមុនហៅថា DED) លំនៅឋានមិនរៀបរយទាំងនោះត្រូវបានកំណត់អត្តសញ្ញាណ និង ត្រូវបានទទួលស្គាល់ថាជាបញ្ហាមួយដ៏សំខាន់ដែលចាំបាច់ត្រូវដោះស្រាយ ដោយការរៀបចំផែនការទីក្រុង។ កិច្ចប្រឹងប្រែងខាងក្រោម ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០០៥៖

- ឆ្នាំ២០០៥: បង្កើតក្រុមការងារបច្ចេកទេស (TWG) ក្រុងសម្រាប់ផ្តល់ការជួយគាំទ្រដល់លំនៅឋានមិនរៀបរយទាំងនោះ។
- ឆ្នាំ ២០០៦: សហគមន៍ចំនួន១៣ត្រូវបានចងក្រង និង បានបង្កើតក្រុមសន្សំប្រាក់។
- តាំងពីឆ្នាំ២០០៧: ការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ និងការបណ្តុះបណ្តាលការងារនៅនឹងកន្លែងជូន ក្រុមការងារបច្ចេកទេសដោយអង្គការ GIZ (អតីត DED)។
- តាំងពីឆ្នាំ២០០៨: ការអនុវត្ត "គម្រោងសាកល្បងតំបន់សួនច្បារ"(LASED[1])។ ការអនុវត្តសាកល្បងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (SLC)ដើម្បីធ្វើបច្ចុប្បន្នភាព និងធ្វើនិយ័តកម្ម លំនៅឋានមិនរៀបរយ ដែលមានស្រាប់។
- ឆ្នាំ ២០០៩: អង្កេតពេញលេញអំពីលំនៅឋានមិនរៀបរយ។
- ឆ្នាំ២០០៩: ទស្សនកិច្ច សិក្សាវាយតម្លៃរបស់ Community Managed Development Partners (CMDP) ទៅកាន់ខេត្តបាត់ដំបង ដើម្បីពង្រឹងអង្គការមិនមែនរដ្ឋាភិបាលតាមមូលដ្ឋាន/ការសន្សំប្រាក់ នៅតាមទីកន្លែងលំនៅឋានមិនរៀបរយនិង ដើម្បី ស្វែងរកដំណោះស្រាយសំរាប់លំនៅឋានជាជម្រើស ផ្សេងៗ។
- ឆ្នាំ២០០៩: CEDT បានផ្តល់ការបណ្តុះបណ្តាលគ្រូឧទ្ទេសស្តីពីការគូសផែនទីសហគមន៍ជូនសហគមន៍ដែលមានលំនៅឋានមិនរៀបរយបានចំនួន ៦។
- តាំងពីឆ្នាំ២០១០: មានការផ្តល់អំណាចជូនសហគមន៍ដូចជា:
  - សម្របសម្រួលសហគមន៍ដែលមានលំនៅឋានមិនរៀបរយបានចំនួន១៣ អោយមានកិច្ចប្រជុំ ប្រចាំខែទៀងទាត់ (CMDP)។

[1] ការបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

- ក្រុមពង្រឹងសិទ្ធិអំណាចនិងអភិវឌ្ឍន៍សហគមន៍ (CEDT) បានផ្តល់ការបណ្តុះ បណ្តាលគ្រូឧទ្ទេសស្តីពីការគូសផែនទីសហគមន៍ជូនសហគមន៍ដែលមានលំនៅឋានមិនរៀបរយ។
- បង្កើតការសម្របសម្រួលយុវជនសហគមន៍ និងក្រុមយុវជនសហគមន៍នៅក្នុងសហគមន៍ (CVS)។

## ២. គំនិតផ្តួចផ្តើមសម្រាប់គម្រោងសាកល្បងស្តីពីការអនុវត្តសារាចរលេខ០៣

ក្នុងខែឧសភា ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តសារាចរណែនាំលេខ០៣ស្តីពី "**ការដំណោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រាន កាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន** "។ សារាចរលេខ០៣នេះ បានដាក់ចេញជំហានចំនួនប្រាំពីរខាងក្រោមជំហានៈ ១ ) ធ្វើអត្តសញ្ញាណកម្មលំនៅឋាន មិនរៀបរយ ២)គូសផែនទីនិងធ្វើចំណាត់ថ្នាក់ទីតាំងដែលបានធ្វើអត្តសញ្ញាណកម្ម៣ ,)ធ្វើសម្ភាសន៍គ្រួសារ, ៤)អភិវឌ្ឍជម្រើសដំណោះស្រាយសម្រាប់ទីតាំងនីមួយៗ (អភិវឌ្ឍន៍នៅនឹងកន្លែង ឬ ផ្លាស់លំនៅឋាន), ៥)ធ្វើផែនការអភិវឌ្ឍន៍នៅកន្លែង ឬ ផែនការតាំងទីលំនៅថ្មី, ៦)រៀបចំហេដ្ឋារចនាសម្ព័ន្ធ និង សេវាសាធារណៈសំខាន់ៗនៅទីកន្លែងទាំងនោះ , ៧)កំណត់ពេលវេលា និងការចូលរួមរបស់ភាគីពាក់ព័ន្ធផ្សេងៗ។

នៅពេលដែលសារាចរលេខ០៣ត្រូវបានអនុម័ត ជំហានដំបូងចំនួន៣ (ពី១ដល់៣) ក្នុងជំហានចំនួន៧ត្រូវបានបំពេញរួចហើយនៅក្រុងបាត់ដំបង។ ការអនុវត្តសារាចរលេខ០៣ គឺផ្អែកលើបទពិសោធន៍របស់ Urban Poor Development Fund ក្នុងការពង្រឹងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តដឹកនាំដោយសហគមន៍ ដែលអាចចរចារជាមួយអាជ្ញាធរដើម្បីរកដំណោះស្រាយលំនៅឋាន និង ការអនុវត្តជាគោលការណ៍ ជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់រាជរដ្ឋាភិបាលកម្ពុជា។

## ២១.តួនាទីអភិបាលកិច្ចល្អរបស់សាលាក្រុងបាត់ដំបង– ការអនុញ្ញាតអភិវឌ្ឍន៍នៅនឹងកន្លែង

សារាចរលេខ០៣ ផ្តល់យុត្តាធិការផ្លូវច្បាប់ជូនអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីដោះស្រាយបញ្ហាលំនៅឋានមិនរៀបរយជាមួយពហុជម្រើសដំណោះស្រាយ។ សារាចរនេះលុបបំបាត់ឧបសគ្គនៃការទទួលខុសត្រូវមិនច្បាស់លាស់រវាងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបើកឱកាសឲ្យសាលាក្រុងបាត់ដំបងប្រែក្លាយឆន្ទៈរបស់ខ្លួនទៅជាការពិតជាក់ស្តែង។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១០សាលាក្រុងបាត់ដំបងបានសម្រេចចិត្តផ្តល់ការអនុញ្ញាតដល់ការអភិវឌ្ឍនៅនឹងកន្លែងជូនដល់តំបន់ដែលមានលំនៅឋានមិនរៀបរយចំនួន ១០ និងបានជ្រើសរើសលំនៅឋាន មិនរៀបរយ ចំនួន ៤ ទៀតជាសហគមន៍គោលដៅសម្រាប់គម្រោងសាកល្បងលើការអនុវត្តសារាចរលេខ ០៣។

## ២២. ចម្លើយជាវិជ្ជមានពីសហគមន៍

### ២១.២. ពង្រឹងការសន្សំប្រាក់សហគមន៍

ក្រោយពេលមានការអនុញ្ញាតឲ្យអភិវឌ្ឍនៅនឹងកន្លែង ការសន្សំប្រាក់សហគមន៍ត្រូវបានកែលម្អ។ តារាងខាងក្រោមបង្ហាញថា តើការសន្សំប្រាក់សហគមន៍ត្រូវបានកែលម្អយ៉ាងដូចម្តេច ក្រោយពេលប្រកាសពីការអភិវឌ្ឍនៅនឹងកន្លែងសម្រាប់លំនៅឋាន មិនរៀបរយក្នុងខែវិច្ឆិកា ឆ្នាំ២០១០។

**តារាង ១ :ការពង្រឹងការសន្សំប្រាក់(គិតជាប្រាក់រៀល)**

| ខែ | សុខសាន្តត្បូង | | សន្តិភាព | | អណ្តូងចេញ | |
|---|---|---|---|---|---|---|
| | សមាជិកសន្សំប្រាក់ | ប្រាក់សន្សំសរុប | សមាជិកសន្សំប្រាក់ | ប្រាក់សន្សំសរុប | សមាជិកសន្សំប្រាក់ | ប្រាក់សន្សំសរុប |
| ឆ្នាំ ២០១០ | | | | | | |
| តុលា | ៨ | ១៨.០០០ | ២៩ | ៧៨.៥០០ | សកម្មភាពសន្សំប្រាក់ធ្វើមិនទាន់បានល្អ ដោយសារមានវិវាទក្នុងសហគមន៍។ វិវាទក្នុងសហគមន៍ត្រូវបានដោះស្រាយ ដោយមានជំនួយពីសហគមន៍ផ្សេងក្នុងខែធ្នូ ឆ្នាំ២០១០។ | |
| វិច្ឆិកា | ១០ | ៣៦.០០០ | ២៩ | ៧៣.០០០ | | |
| ធ្នូ | ១៤ | ៣៥.០០០ | ២៨ | ១០៩.៥០០ | | |
| ២០១១ | | | | | | |
| មករា | ២១ | ១២៤.០០០ | ៣៦ | ១៩៣.០០០ | ៣០ | ១៣៩.០០០ |
| កុម្ភៈ | ២៥ | ១៤២.០០០ | ៤៣ | ១៥៦.៥០០ | ៣៥ | ១៤០.០០០ |
| មីនា | ២៨ | ១៤៥.០០០ | ៥០ | ២០៧.០០០ | ៤៥ | ២១០.០០០ |
| មេសា | ១៣ | ៣៨.០០០ | ៥២ | ២២៤.០០០ | ៧០ | ឆ្នាំ ២០០.០០០ |

## ២ ការអភិវឌ្ឍ ២.២.ដោយផ្អែកលើ ធនធានសហគមន៍ - យើងគ្រប់ផ្នែក មិនរហាមទេ

តារាងខាងក្រោមបង្ហាញការអភិវឌ្ឍដែលដឹកនាំដោយសហគមន៍ផ្អែកលើធនធានសហគមន៍ ១០០%។

**តារាង ២: អភិវឌ្ឍន៍ផ្អែកលើធនធានសហគមន៍**

| លរ. | សហគមន៍ | ទំហំ | ថ្លៃចំណាយ | វិភាគទានរបស់សហគមន៍ |
|---|---|---|---|---|
| សម្អាតសំរាមក្នុងសហគមន៍ | | | | |
| បរិស្ថាន | | | | |
| ១ | សុខសាន្តត្បូង | សហគមន៍ទាំងមូល | អ្នកស្ម័គ្រចិត្តសហគមន៍៥៧ នាក់ | កម្លាំងពលកម្មរបស់សហគមន៍ ១០០% |
| ២ | សុខសាន្តជើង | សហគមន៍ទាំងមូល | អ្នកស្ម័គ្រចិត្តសហគមន៍៤០ នាក់ រួមមាននារី២៥នាក់ | កម្លាំងពលកម្មរបស់សហគមន៍ ១០០% |
| ៣ | វាសនាអមតៈ | សហគមន៍ទាំងមូល | យុវជនសហគមន៍និងអ្នកស្ម័គ្រចិត្តសហគមន៍៨២ នាក់ | កម្លាំងពលកម្មរបស់សហគមន៍ ១០០% |
| ៤ | ឯកភាព | សហគមន៍ | អ្នកស្ម័គ្រចិត្តសហគមន៍៣០ នាក់ | កម្លាំងពលកម្មរបស់ |

| | | | | |
|---|---|---|---|---|
| | | ទាំងមូល | | សហគមន៍ ១០០% |
| **សម្អាតលូទឹក** | | | | |
| ១ | **សុខសាន្តជើង** | ២០mx០៦,m | អ្នកស្ម័គ្រចិត្តសហគមន៍២៣ នាក់ | កម្លាំងពលកម្មរបស់សហគមន៍ |
| ២ | **សន្តិភាព** | ១៧៤mx១m | $៣៦៧៥,+អ្នកស្ម័គ្រចិត្តសហគមន៍ | ១០០% |
| **កែលម្អផ្លូវថ្នល់** | | | | |
| ១ | **សុខសាន្តជើង** | ២១០m x ៤m (ក្រោយពេលរើផ្ទះពីផ្លូវរថភ្លើង) | $៧២៥០០, | ១០០% |
| ២ | **វាសនាអមតៈ** | ៣០mx៤m | $២៣០ | ១០០% |
| ៣ | **សន្តិភាព** | ៩៤mx៤m | $១៩៥ + កម្លាំងពលកម្មរបស់សហគមន៍ | ១០០% |
| ៤ | **ឯកភាព** | ១៦១mx៣៥m | $១២០ + កម្លាំងពលកម្មរបស់សហគមន៍ | ១០០% |
| ៥ | **វាសនាអមតៈ** | កន្លែងចាក់សំរាមនៅកន្លែងមានសំរាមនៅលើផ្លូវថ្នល់ | កម្លាំងពលកម្មរបស់សហគមន៍ | ១០០% |
| **ការសាងសង់លូទឹក** | | | | |
| ១ | **ឯកភាព** | ៥៨២៣៦,m | $៥៩៣,៤១៧. | ១០០% |

## ២៣. ០៣ការបង្កើតសម្ព័ន្ធភាពការងារស្តីពីការអនុវត្តសារាចរលេខ

ដើម្បីពង្រឹងកិច្ចប្រឹងប្រែងរួមនៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ក្នុងការបំពេញបន្ថែមការងារគ្នា លើការអនុវត្តសារាចរលេខ ០៣ ជាមួយទស្សនៈ **ពួតដៃគ្នាក្នុង**វេទិកាក្រៅប្រព័ន្ធមួយ សម្ព័ន្ធភាព" "០៣ការងារស្តីពីការអនុវត្តសារាចរលេខ ត្រូវបានបង្កើតឡើង ក្នុងខែកុម្ភៈ ឆ្នាំ២០១១ ដោយមានសមាជិកដូចជា CMDP, CEDT, CVS, SLG, GIZ, វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum), UN Habitat, HFH, UNOCHR និង COHRE។ CMDP កំពុងបំពេញមុខងារជាលេខាធិការដ្ឋានសម្រាប់សម្ព័ន្ធភាពការងារនេះ។

## ៣. ការជួយគាំទ្ររបស់ម្ចាស់ជំនួយចាំបាច់ត្រូវធ្វើឲ្យមានតុល្យភាពថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនៃរាជរដ្ឋាភិបាលកម្ពុជា

សមិទ្ធផលក្នុងរយៈពេលដ៏ខ្លីនេះនៅខេត្តបាត់ដំបងពាក់ព័ន្ធនឹងគម្រោងសាកល្បងលើ សារាចរលេខ ០៣ គឺជាភស្តុតាងច្បាស់លាស់ថា ថ្នាក់ជាតិគឺមានតួនាទីសំខាន់សម្រាប់ការរៀបចំគោលនយោបាយ ហើយថ្នាក់ក្រោមជាតិគឺមានតួនាទីសំខាន់សម្រាប់ការអនុវត្តគោលនយោបាយ ដែលរួម បញ្ចូលទាំងអាជ្ញាធរមូលដ្ឋាន សហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្តែ ការជួយគាំទ្រទាំងអស់ ភាគច្រើនរបស់ម្ចាស់/ជំនួយ គឺមាននៅថ្នាក់ជាតិ ដោយមានការមើលរំលងយន្តការ D&D និងតួនាទីរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និង សហគមន៍ នៅក្នុងការអនុវត្តគោលនយោបាយនេះ។ ការជួយគាំទ្រ ពុំទាន់មានតុល្យភាពនេះ គឺពិតជាជម្រុញ **មជ្ឈការ** ជាជាងវិសហមជ្ឈការហើយម្ចាស់ជំនួយចាំបាច់ត្រូវផ្លាស់ប្តូរការអនុវត្តបច្ចុប្បន្ន ដោយធ្វើឲ្យមានតុល្យភាព រវាងការជួយគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយយន្តការមួយដែលអាចផ្តល់ការជួយគាំទ្រផ្ទាល់ជូនអាជ្ញាធរថ្នាក់ក្រោមជាតិ សហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល។

## ៤. មាតិកា ទិសដៅអនាគត – សង្ខេប

### ៤១. រយៈពេលខ្លី (ចុងឆ្នាំ២០១១):

- លើកទឹកចិត្តនិងពង្រីកការគៀងគរសហគមន៍នៅក្នុងសហគមន៍គោលដៅចំនួន ១០
- ចងក្រងឯកសារអំពីហេដ្ឋារចនាសម្ព័ន្ធទីក្រុងដើម្បីកំណត់លក្ខខណ្ឌសម្រាប់ការអភិវឌ្ឍពីក្រៅ
- សម្រេចអំពីសុវត្ថិភាពកាន់កាប់រយៈពេលខ្លីលើមូលដ្ឋាននៃការអភិវឌ្ឍទីក្រុងនាអនាគត

### ៤២. រយៈពេលមធ្យម (២០១២ – ២០១៣)

- ពង្រីកការអនុវត្តល្អនៅកម្រិតទូទាំងទីក្រុង
- កំណត់ដំណោះស្រាយលំនៅឋានអចិន្ត្រៃយ៍ហួសពីសុវត្ថិភាពកាន់កាប់រយៈពេលខ្លី
- ប្រែក្លាយឲ្យទៅជាផ្លូវការ និងជាលក្ខណៈស្ថាប័ននូវយន្តការដំណើរការ/ផ្តល់សេវាដែលបានកំណត់ឬរកឃើញនៅក្នុងការអនុវត្តជាក់ស្តែង
- ផ្តល់អនុសាសន៍ដើម្បីកែលម្អសារាចរលេខ០៣ ផ្អែកលើការអនុវត្តគម្រោងសាកល្បង និងពង្រីកទៅដល់តំបន់ដទៃទៀតនៃប្រទេសកម្ពុជា។

### ៤៣. រយៈពេលវែង (ក្រោយឆ្នាំ ២០១៤)

- គម្រោងសាកល្បងលើលំនៅឋានមានតម្លៃថោក ដោយសារមានកំណើនប្រជាជន និងចំណាកស្រុកពីជនបទមកទីក្រុង
- ខេត្តបាត់ដំបងជាគម្រូមួយនៃលំនៅឋានមានតម្លៃសមរម្យសម្រាប់ជនគ្រប់រូប
- ប្រែក្លាយជាទីក្រុងរុងរឿងមួយដែលការអភិវឌ្ឍន៍មានលក្ខណៈទ្រទ្រង់ប្រជាជនក្រីក្រ

ព័ត៌មានទំនាក់ទំនង

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងសម្ព័ន្ធភាពការងារស្តីពីការអនុវត្តសារាចរលេខ០៣**

Abdul Rashid Khatri (**ទីប្រឹក្សា**)

Community Managed Development Partners (CMDP)

**ទូរស័ព្ទចល័តៈ**+855 12 472 909

Email: khatriab@yahoo.com

# បំណុលក្រៅប្រទេសរបស់កម្ពុជាៈ តើវាជាបញ្ហាគួរឲ្យបារម្ភមួយឬទេ ?[2]

អត្ថបទនេះ ត្រូវបានសរសេរ ឡើងក្នុងគោលបំណងជូនព័ត៌មានដល់អ្នកអានជាទូទៅ ដែលចាប់អារម្មណ៍លើការស្វែងយល់ ឬ ធ្វើការសិក្សាបន្ថែមទៀត និងជំរុញឲ្យមានការជជែកពិភាក្សាអំពីបំណុលសាធារណៈនៅប្រទេសកម្ពុជា។ ដោយ យោងលើព័ត៌មាននៃឯកសារដែលមានស្រាប់ អត្ថបទនេះបានព្យាយាមដាក់បញ្ចូលដោយសង្ខេបនូវរបកគំហើញស្រាវជ្រាវដែលមានស្រាប់ អំពីមូលហេតុដែលប្រទេសខ្ចីបុលសាធារណៈពីក្រៅប្រទេស ស្ថានភាពបច្ចុប្បន្ន និង បញ្ហានៃបំណុល និងនិរន្តរភាពបំណុលរបស់កម្ពុជា ។

## មូលហេតុដែលប្រទេសដូចកម្ពុជាខ្ចីបុលបរទេសឬបុលពីក្រៅប្រទេស

ដូចប្រទេសកំពុងអភិវឌ្ឍដទៃផ្សេងដែរ ប្រទេសកម្ពុជាស្ថិតនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍរបស់ខ្លួន តម្រូវការមូលធនបរទេសមានសារៈសំខាន់ណាស់ដើម្បីដោះស្រាយគម្លាត ដែលអាចមាន ចំនួនបីនៅក្នុងសេដ្ឋកិច្ច (Malcolm et al,១៩៩៦)។ ទីមួយ លំហូរចូលមូលធនបរទេស អាចធ្វើហិរញ្ញប្បទានលើគម្លាតអត្រាប្តូរប្រាក់បរទេស ដែលភាគច្រើនគឺជាឱនភាពជញ្ជីងពាណិជ្ជកម្ម ដោយ ការនាំចូលតិចជាងការនាំចេញទំនិញ និងសេវាមិនមែនកត្តាផលិតកម្ម។ ទីពីរ មូលធនបរទេសអាចធ្វើហិរញ្ញប្បទានលើគម្លាតរវាងការវិនិយោគ និងប្រាក់សន្សំក្នុងស្រុក ដែលមានន័យថា ទំហំនៃការសន្សំក្នុងស្រុកមានកម្រិតទាប ហើយមានទំហំ តំរូវការលើមូលធនមាន កម្រិតខ្ពស់ជាងដែលចាំបាច់សម្រាប់ធ្វើហិរញ្ញប្បទានវិនិយោគ។ ទីបី ការខ្ចីបុលបរទេសក៏អាចធ្វើហិរញ្ញប្បទានផងដែរនូវឱនភាពថវិការដ្ឋាភិបាល ដែលជាធម្មតាគឺ នៅក្នុងទម្រង់នៃការបំពេញនូវការវិនិយោគសាធារណៈដែល ចាំបាច់ ឬ ការសងបំណុលចាស់។ ជាបទពិសោធន៍សមត្ថភាពក្នុងការយកពន្ធរបស់រដ្ឋាភិបាលនៃប្រទេសកំពុង អភិវឌ្ឍន៍ក៏មិនមានលក្ខណៈគ្រប់គ្រាន់ផងដែរ នៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ។ រៀងរាល់ឆ្នាំ ប្រទេសកម្ពុជារកចំណូលបានប្រហែល១២-១៣%នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)ដែលមានលក្ខណៈទាប បើប្រៀបធៀបទៅប្រទេសដទៃទៀតនៅអាស៊ីអគ្នេយ៍។

ក្រៅពីធនធានហិរញ្ញប្បទានពីប្រភពខាងក្រៅប្រទេស រាជរដ្ឋាភិបាលអាចខ្ចីបុលពីប្រភពក្នុងស្រុក (ពោលគឺ ពីប្រជាពលរដ្ឋខ្លួន និង/ឬផ្នែកឯកជន ) តាមរយៈការចេញមូលប័ត្ររបស់រដ្ឋាភិបាលដោយមានបង់ការប្រាក់ ហើយរដ្ឋាភិបាលអាចបង្គរបំណុលក្នុងរយៈពេលមួយផងដែរ ប្រសិនបើអ្នកកាន់មូលប័ត្រឬប្រជាពលរដ្ឋដែលទិញមូលប័ត្ររដ្ឋាភិបាល បន្តមានជំនឿលើស្ថេរភាពរបស់រដ្ឋាភិបាលនិងលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការសងត្រឡប់ទៅវិញលើមូលប័ត្រនីមួយៗ។ ប្រសិនបើមានផលប៉ះពាល់ខ្លាំងដោយសារ

---

[2] អត្ថបទនេះភាគច្រើនទាក់ទិននឹងមូលហេតុទូទៅនិងបញ្ហានៃបំណុលសាធារណៈពីក្រៅប្រទេស ត្រូវបានដកស្រង់ចេញពី Stuart R.Lynn (ឆ្នាំ ២០០៣)។ អភិវឌ្ឍសេដ្ឋកិច្ចៈ ទ្រឹស្តីនិងការអនុវត្តសម្រាប់ពិភពលោកដែលមានការបែងចែក។ Prentice Hall, New Jersey, USA។

អតិផរណាបណ្តាលមកពីឱនភាពថវិកានៅពេលមានតម្រូវការខ្លាំង បំណុលធំឬកំណើននៅក្នុងបំណុលរបស់រដ្ឋាភិបាលអាចធ្វើឲ្យកើនឡើងនូវអត្រាការប្រាក់ និង ធ្វើឲ្យចង្អៀតដល់ការខ្ចីបុលរបស់ផ្នែកឯកជន។ បំណុលក្នុងស្រុករបស់ប្រទេសកម្ពុជានៅតែមានលក្ខណៈតិចនៅឡើយគិតមកដល់ឆ្នាំ២០១១[3]។ គេគប្បីកត់សម្គាល់ថាភាពខុសគ្នាសំខាន់មួយរវាងបំណុលសាធារណៈនិងបំណុលឯកជនគឺសិទ្ធិស្របច្បាប់របស់ម្ចាស់បំណុលក្នុងការទាមទារឲ្យកូនបំណុលសងត្រឡប់មកវិញនូវប្រាក់កម្ចីទាំងឡាយ ប្រសិនបើគ្មានលទ្ធភាពសង។ ប្រសិនបើក្រុមហ៊ុនមួយក្ស័យធន និង គ្មានលទ្ធភាពសងបំណុល ដោយប្រកាសភាពអសមត្ថភាពរបស់ខ្លួនក្នុងការសង អ្នកកាន់មូលប័ត្រមាន សិទ្ធិស្របច្បាប់ក្នុងការឃាត់ទុកនិងចាត់ចែងការបែងចែកទ្រព្យសកម្មនៅសេសសល់របស់ក្រុមហ៊ុន។ វាអាចគឺជាការលំបាកក្នុងការបង្ខំអនុវត្តការទាមទារនោះលើរដ្ឋាភិបាលមួយ។

## ស្ថានភាពបច្ចុប្បន្ននៃបំណុលក្រៅប្រទេស(សាធារណៈ)នៅប្រទេសកម្ពុជា[4]

គិតមកដល់ខែ មីនា ឆ្នាំ២០១១ បំណុលពីក្រៅប្រទេសដែលកម្ពុជាជំពាក់ (លើកលែងបំណុលដែលជំពាក់ប្រទេសរុស្ស៊ី(៤៥៧លានដុល្លារអាមេរិក) និង សហរដ្ឋអាមេរិក (១៦២លានដុល្លារអាមេរិក)) ក្នុងទម្រង់ជាប្រាក់កម្ចីសម្បទានបានបង្គរដល់ចំនួន៣,៦៧ពាន់លានដុល្លារអាមេរិក ដែលនៅក្នុងនោះប្រាក់ចំនួន ០,៦២១ពាន់លានដុល្លារអាមេរិក ឬ ៦២១លានដុល្លារអាមេរិកគឺជាគម្រោង/កម្ចីមិនទាន់អនុវត្ត។ ដោយដកចំនួនគម្រោង/កម្ចីមិនទាន់អនុវត្តនេះចេញ បំណុលពីក្រៅប្រទេស ឬ ប្រាក់កម្ចីសម្បទានសរុបដែលត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់ក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍កម្ពុជា (www.cdc-crdb.gov.kh ឬ http://cdc.khmer.biz) គឺមានចំនួន ៣,០២ពាន់លានដុល្លារអាមេរិក។ លក្ខខណ្ឌនៃការសងបំណុលដែលជំពាក់ប្រទេសទាំងពីរខាងលើ (៦១៩លានដុល្លារអាមេរិក) ស្ថិតនៅក្រោមការចរចាររវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសទាំងពីរ។ ការវិភាគ លក្ខខណ្ឌនៃជំនួយដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា[5]ក្នុងឆ្នាំ២០១០បានបង្ហាញថា នៅក្នុង ចំណោមម្ចាស់ជំនួយទ្វេភាគីនិងពហុភាគីដែលផ្តល់ប្រាក់កម្ចីសម្បទានជូនប្រទេសកម្ពុជាប្រទេស ចិនគឺជាម្ចាស់ជំនួយទ្វេភាគីថ្មី

---

[3]ធនាគារអភិវឌ្ឍន៍អាស៊ី (២០១១)។ ប្រមើមើលការអភិវឌ្ឍន៍នៅអាស៊ី ឆ្នាំ២០១១ (ស្តីពីប្រទេសកម្ពុជា)។ ទំព័រ១៨២។ សូមមើល www.adb.org។របាយការណ៍នេះដាក់កម្រិតបច្ចុប្បន្ននៃបំណុលសាធារណៈរបស់ប្រទេសកម្ពុជាថាអាចគ្រប់គ្រងបាន ហើយបំណុលនេះត្រូវបានប៉ាន់ស្មានថាមានចំនួន ៣,៥ពាន់លានដុល្លារអាមេរិករហូតដល់ចុងឆ្នាំ២០១០។ កម្ចីពីសាធារណរដ្ឋប្រជាមានិតចិនមានទំហំប្រហែល៥៨% នៃការកម្ចីទ្វេភាគីសរុបដែលបានចំណាយក្នុងឆ្នាំ២០១០។ ប្រការនេះបង្ហាញភាពចាំបាច់ឲ្យប្រទេសកម្ពុជាធ្វើឲ្យមានតុល្យភាពនូវប្រភពបំណុលសាធារណៈ។

[4] បំណុលបរទេសសាធារណៈ គឺសំដៅលើ "បំណុលរយៈពេលវែងសាធារណៈនិងបំណុលដែលត្រូវបានធានាជាសាធារណៈ ពោលគឺបំណុលដែលមានកាលវសាន្តរយៈពេលចាប់ពី១ឆ្នាំឡើងទៅ ដែលជំពាក់ដោយរដ្ឋាភិបាល ឬ ដោយផ្នែកឯកជន និង ត្រូវបានធានាដោយរដ្ឋាភិបាលរបស់ខ្លួន។

[5] ព្រឹត្តប័ត្រព័ត៌មានស្តីពីលក្ខខណ្ឌជំនួយនៃកម្ចីសម្បទានបរទេសចំពោះប្រទេសកម្ពុជា ដែលត្រូវបានផលិតនៅចុងឆ្នាំ២០១០ និងព័ត៌មានអំពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អាចមើលបានតាមគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា www.ngoforum.org.kh។

មួយ[6] ដែលផ្តល់លក្ខខណ្ឌជំនួយដែលមានលក្ខណៈអំណោយផលតិចជាងគេ។ ជាមួយព័ត៌មានដែលមានកំណត់ស្តីពីគម្រោងកម្ចីសម្បទាន ប្រទេសចិនយកអត្រាការប្រាក់ប្រចាំឆ្នាំខ្ពស់ជាងគេរហូតដល់២%ក្នុងមួយឆ្នាំ និង រយៈពេលអនុគ្រោះនិងរយៈពេលសងរំលោះខ្លីជាងគេ បើប្រៀបធៀបទៅនឹងម្ចាស់ជំនួយប្រពៃណីផ្សេងទៀត (ដូចជាសហភាពអឺរ៉ុប ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ប្រទេសជប៉ុន ) និង ម្ចាស់ជំនួយថ្មី ដូចជាប្រទេសកូរ៉េខាងត្បូងជាដើម។

Stuart R.Lynn (ឆ្នាំ ២០០៣) បានដកស្រង់ចំណាត់ថ្នាក់ប្រទេសដែលធ្វើការសិក្សាស្រាវជ្រាវដោយធនាគារពិភពលោកថាតើប្រទេសទាំងនេះជំពាក់បំណុលធ្ងន់ធ្ងរ មធ្យម ឬ តិច។ ចំណាត់ថ្នាក់ ជំពាក់បំណុល" ត្រូវបានផ្តល់ចំពោះប្រទេសណាដែលបំពេញលក្ខណៈវិនិច្ឆ័យបីនៃលក្ខណៈវិនិច្ឆ័យ "ធ្ងន់ធ្ងរទាំងបួនខាងក្រោមៈ ១) អនុបាតបំណុលប្រៀបធៀបទៅនឹងផលិតផលជាតិសរុប(GNP) /ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.)ស្មើ ៥០ភាគរយ ឬ ច្រើនជាង ,២) អនុបាតបំណុលប្រៀបធៀបទៅនឹងការនាំចេញស្មើ២៧៥ភាគរយ ឬ ច្រើនជាង ៣ ,) អនុបាតកាតព្វកិច្ចសងបំណុល(រំលោះបំណុល)ប្រៀបធៀបទៅនឹងការនាំចេញស្មើ៣០ភាគរយ ឬ ច្រើនជាង និង ៤ )អនុបាតទំហំការប្រាក់នៃបំណុលដែលត្រូវសងប្រៀបធៀបទៅនឹងការនាំចេញស្មើនឹង២០ភាគរយ ឬ ច្រើនជាង។ គិតមកដល់ឆ្នាំ២០១០ ស្ថានភាពរបស់ប្រទេសកម្ពុជានៅតែស្ថិតនៅឆ្ងាយខាងក្រោយសូចនាករឬកម្រិតកំណត់នៃវិបត្តិបំណុលទាំងនេះ។ ចំណុចនេះត្រូវបានគូសបញ្ជាក់បន្ថែមដោយការវិភាគរួមនៃធនាគារពិភពលោក ) WB(/មូលនិធិរូបិយវត្ថុអន្តរជាតិ )IMFលើនិរន្តរភាពបំណុល ((DSA) ឆ្នាំ២០១០ ដែលថាវិសាលភាពរបស់ប្រទេសកម្ពុជាក្នុងការជួបប្រទះនឹងហានិភ័យបន្ថែមពីការខ្ចីបុលបន្ថែមពីបរទេសនឹងត្រូវបានកាត់បន្ថយយ៉ាងច្រើន ដោយសាររាជរដ្ឋាភិបាលបានវិល ត្រឡប់ទៅកាន់កម្រិតដើមស្របច្បាប់សម្រាប់ការខ្ចីបុលថ្មីចំនួន ២០០លាន SDR[7] ក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១០។ ប៉ុន្តែក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១១ កម្រិតស្របច្បាប់នៃការខ្ចីបុលថ្មី (បំណុលពីក្រៅប្រទេស) បានកើនឡើងដល់៤០០លាន SDR។ ប្រការនេះមានន័យថា ប្រសិនបើចំនួននៃការខ្ចីបុលថ្មីពិតជាឡើងដល់កម្រិតអតិបរមានៃកម្រិតស្របច្បាប់នោះមែន ហើយ អត្រាកំណើនរបស់វាគឺកើនលឿនជាងសូចនាករឬកម្រិត កំណត់ទាំងនោះជាពិសេស ផ ស និង ចំណូល.ស.វាទំនងជានឹងធ្វើឲ្យកើនឡើងនូវកម្រិតខ្ពស់នៃបំណុលពីក្រៅប្រទេស និងកម្រិតកំណត់នៃសូចនាករសម្រាប់ប្រទេសកម្ពុជានៅក្នុងការវិភាគចិរភាពបំណុលលើកក្រោយ។

---

[6]ប្រាក់កម្ចីសម្បទានសំដៅលើប្រាក់កម្ចីទាំងឡាយដែលត្រូវបានផ្តល់ក្នុងអាណត្តិសម្បទាន ដែលរួមមានការយកអត្រាការប្រាក់ទាបជាងអត្រាទីផ្សារ និង មានសមាសភាគជំនួយឥតសំណងយ៉ាងហោចណាស់២៥ភាគរយ ដែលត្រូវបានគណនាតាមអត្រាបញ្ចុះតម្លៃ១០ភាគរយ ឬ ប្រៀបធៀបទៅនឹងអត្រាយោងចង្អុល១០ភាគរយក្នុងមួយឆ្នាំ។ សមាសភាគជំនួយឥតសំណងមិនត្រូវបានកត់ត្រាជាលំហូរទេ។ សម្រាប់ព័ត៌មានលម្អិតតអំពីការគណនាសមាសភាគជំនួយឥតសំណងសូមមើល www.oecd.org ឬ www.worldbank.org ។

[7] SDR: សិទ្ធដកប្រាក់ពិសេស គឺជាស្តង់ដាររូបិយប័ណ្ណដែលត្រូវបានប្រើនៅក្នុងប្រព័ន្ធមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ អត្រាប្តូរប្រាក់សម្រាប់ថ្ងៃទី៣០ខែ មីនា ឆ្នាំ២០១០គឺ ១ ដុល្លារអាមេរិក = SDR ០,៦៣៣០៣៣ ឬ ១ SDR = ១,៥៨ ដុល្លារអាមេរិក។ សូមមើលwww.bankofcanada.ca/en/rates/exchform.html។

ការវិភាគរួមនៃធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ )IMFលើនិរន្តរភាពបំណុល ((DSA) ឆ្នាំ២០១០បានចាត់ថ្នាក់បំណុលបរទេសសាធារណៈរបស់កម្ពុជាគិតដល់ចុងឆ្នាំ២០០៩ថាមានហានិភ័យកំរិតមធ្យមនៃការជួបប្រទះប្រឈមនឹងវិបត្តិបំណុល ទោះបីជាយ៉ាងណាក៏ដោយ ភាពបង្គរនៃបំណុលបរទេសសាធារណៈរបស់កម្ពុជាក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះបានកើនឡើងបើគិតជាភាគរយ ធៀបទៅនឹងចំណូលថវិកាជាតិសរុប និង ផ ស.ស.ដែលឆ្ពោះទៅកាន់កម្រិតកំណត់នៃសូចនាករ (សូមមើលតារាងខាងក្រោម តាមការវាស់វែងដោយការវាយតម្លៃគោលនយោបាយនិងស្ថាប័នប្រទេស ។ ម្យ៉ាងទៀត((CPIA) របស់ធនាគារពិភពលោកបង្ហាញថា គោលនយោបាយនិងស្ថាប័នរបស់កម្ពុជា ទទួលបានពិន្ទុជាមធ្យម ៣ ២៦,ក្នុងអំឡុងពេលបីឆ្នាំកន្លងមក ដែលលើសកម្រិតកំណត់៣ បន្តិច។ ហេតុដូច្នេះ ប្រទេសកម្ពុជាត្រូវបាន ២៥, " ចាត់ថ្នាក់ថាជាអ្នកអនុវត្តទន់ខ្សោយ-Weak Performerមួយស "ម្រាប់ឆ្នាំសារពើពន្ធ២០០៩។ ចំណាត់ថ្នាក់នេះត្រូវបានផ្អែកលើកម្រិតកំណត់ evitacidni tnedneped ycilop) thresholds( ផ្អែកលើគោលនយោបាយពាក់ព័ន្ធក្រោមទិន្នភាពឬសេណារ៉ូគោល(baseline scenario)។ ចំណាត់ថ្នាក់ DSA ប៉ុន្មានឆ្នាំចុងក្រោយនេះដែលកំណត់ថាប្រទេសកម្ពុជាមានហានិភ័យមធ្យម ក៏ត្រូវបានពន្យល់មួយផ្នែកផងដែរដោយលក្ខខណ្ឌសម្បទាននៃការសងបំណុល ដែលត្រូវបានផ្តល់ដោយម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី។ ក្របខ័ណ្ឌនិរន្តរភាពបំណុលនៃប្រទេសមានប្រាក់ចំណូលទាប(LIC DSF)ទទួលស្គាល់ថាគោលនយោបាយនិងស្ថាប័នល្អប្រសើរអនុញ្ញាតឲ្យប្រទេសអាចគ្រប់គ្រងបំណុលដែលមានកម្រិតខ្ពស់ជាង ដូច្នេះ កម្រិតកំណត់សម្រាប់សូចនាករបំណុល គឺអាស្រ័យលើគោលនយោបាយ " the threshold levels for debt indicators are policy dependent" ។

| ប្រទេសកម្ពុជាៈសូចនាករបំណុលសាធារណៈបរទេសនៅចុងឆ្នាំ ២០០៩ | | |
|---|---|---|
| | កម្រិតកំណត់ (Indicative Thresholds) | ចុងឆ្នាំ ២០០៩ (កម្ពុជា) |
| តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុលគិតជាភាគរយនៃៈ | | |
| ផស.ស. | ៣០ | ២២ |
| ការនាំចេញ | ១០០ | ៤១ |
| ចំណូល | ២០០ | ១៨៩ |
| សងបំណុល[8], គិតជាភាគរយនៃៈ | | |
| ការនាំចេញ | ១៥ | ១ |
| ចំណូល | ២៥ | ៥ |

ប្រភពៈ អាជ្ញាធរកម្ពុជា និង ការប៉ាន់ស្មានរបស់បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ )IMFនិងធនាគារពិភពលោក។ (ដកស្រង់ពីការវិភាគរួមនៃធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ ) IMFលើនិរន្តរភាព (ឬចិរភាពបំណុល ( DSA ) ឆ្នាំ២០១០ សម្រាប់ប្រទេសកម្ពុជា។

[8] ការសងរំលោះបំណុលឬកាតព្វកិច្ចបំណុល គឺជាការសងទាំងប្រាក់ដើម និងការប្រាក់។

នៅចុងឆ្នាំ ២០០៩ សន្និធិបំណុលសាធារណៈក្រៅប្រទេសនិងបំណុលដែលត្រូវបានធានាជាសាធារណៈ (PPG) របស់កម្ពុជា គឺមានកម្រិតប្រហែល២៨ភាគរយនៃផ ស.ស.នាមករណ៍ (Nominal GDP) និង ២២ភាគរយ គិតជាតម្លៃបច្ចុប្បន្នសុទ្ធ(NPV)[9]។ មកដល់ឆ្នាំ ២០០៨ កំណើនសេដ្ឋកិច្ចរឹងមាំ និងស្ថានភាពអំណោយផលនៅក្រៅប្រទេសបានរួមចំណែកដល់ការធ្វើឲ្យធ្លាក់ចុះនៃអនុបាតបំណុល។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីឆ្នាំ ២០០៩ អនុបាតបំណុល PPG ក្រៅប្រទេសបានកើនឡើង ដែលមួយផ្នែកឆ្លុះបញ្ចាំងកំណើនជំនួយពីម្ចាស់ជំនួយបច្ចុប្បន្ននិងម្ចាស់ជំនួយថ្មី នៅក្នុងខណៈពេលនៃការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក។ ជាលទ្ធផល តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងចំណូលគឺប្រហែល១៨៩ភាគរយ ដែលខិតកាន់តែជិតដល់កម្រិតកំណត់ ២០០ ភាគរយ។ សម្រាប់ឆ្នាំ២០១០សន្និធិបំណុលគិតតាមតម្លៃបច្ចុប្បន្នជាភាគរយនៃផ ស ជា.ស.ភាគរយនៃការនាំចេញទំនិញនិងសេវាកម្មមិនមែនកត្តាផលិតកម្ម និងជាភាគរយនៃចំណូលថវិកាជាតិ របស់រាជរដ្ឋាភិបាលត្រូវបានព្យាករណ៍ ក្នុងកម្រិត២៣ភាគរយ ៤២ភាគរយ និង ១៧៨ភាគរយ រៀងៗគ្នា។ (ស្រង់ពីការវិភាគរួមនៃធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ )IMFលើ ( និរន្តរភាពឬចិរភាពបំណុល (DSA) ឆ្នាំ ២០១០ សម្រាប់កម្ពុជា)។

## តើអ្វីនៅជាកម្រិតមាននិរន្តរភាពឬចិរភាពនៃបំណុល?

គេពុំឃើញមានចម្លើយងាយចំពោះសំណួរនេះទេ។ សេដ្ឋកិច្ចមួយមានកម្រិតនិរន្តរភាពឬចិរភាពបំណុល ប្រសិនបើសេដ្ឋកិច្ចនោះមានកំណើនដែលមានស្ថិរភាពល្អ ប្រសិនបើការនាំចេញនៃសេដ្ឋកិច្ចកំពុងកើនឡើងលឿនគ្រប់គ្រាន់សម្រាប់ទិញទំនិញនាំចូលចាំបាច់ )ជញ្ជីងពាណិជ្ជកម្មមានតុល្យភាព ឬអតិរេក (និងដើម្បីទប់ទល់នឹងលំហូរចេញមូលធនសុទ្ធរយៈពេលខ្លី និង ប្រសិនបើសេដ្ឋកិច្ចមានស្ថេរភាពអត្រាប្តូរប្រាក់ដែលប្រកបដោយភាពប្រាកដនិយម។ បំណុលរដ្ឋាភិបាលមាននិរន្តរភាព ប្រសិនបើទំហំនៃការសងរំលោះបំណុលនៅតែជាចំណែកតូចមួយនៃថវិកាជាតិរបស់ខ្លួន និងដែលនៅក្នុងនោះ រដ្ឋាភិបាលអាចសងដោយមិនប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ឬ អត្រាកំណើនសេដ្ឋកិច្ច [10]។ ឧទាហរណ៍ ប្រទេសកូរ៉េត្បូង បានខ្ចីបុលយ៉ាងច្រើននិងប្រកបដោយភាពជោគជ័យក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ផ្អែកលើច្បាប់ថវិកាជាតិពីឆ្នាំ ២០០៦ដល់ឆ្នាំ២០១១ការសងបំណុលរបស់កម្ពុជា (ការប្រាក់និងប្រាក់ដើមគិតជាភាគរយនៃ ( ,៣ ចំណាយថវិកាជាតិសរុប នៅតែមានស្ថេរភាពក្នុងកម្រិតជាមធ្យម៣% ប៉ុន្តែ បើគិតជាតម្លៃ វាបានកើនឡើងពី ៣៦ លានដុល្លារអាមេរិក ដល់ ៧៨ លានដុល្លារអាមេរិកក្នុងមួយឆ្នាំក្នុងរយៈពេលដូចគ្នា។ ដើម្បីរក្សាអត្រាភាគរយថេរនៃការសងបំណុល ប្រទេសកម្ពុជាត្រូវតែធានាឲ្យបានថាការខ្ចីបុលថ្មីនឹងត្រូវបានប្រើដើម្បីជម្រុញកំណើនសេដ្ឋកិច្ច ហើយចំណូលនឹងត្រូវបានប្រមូលក្នុងល្បឿនថេរនិងកើនឡើង ឬ យ៉ាងហោចណាស់ ក្នុងល្បឿនស្មើគ្នានៃកំណើនបំណុលដែរ ប្រសិនបើកម្ពុជាចង់រក្សាកម្រិតបំណុលនេះតាមភាគរយនៃ

---

[9] សម្រាប់រូបមន្តអំពីរបៀបគណនាតម្លៃបច្ចុប្បន្នសុទ្ធ (NPV) សូមមើលគេហទំព័រធនាគារពិភពលោក(www.worldbank.org) និងរកមើល `How to do DSA for Low-Income Countries (2006)´។

[10]សូមព័ត៌មានលម្អិតនៅក្នុងការវិភាគរួមនៃធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) លើនិរន្តរភាពបំណុលឆ្នាំ២០១០ដែលអាចទាញយកបានពីគេហទំព័រwww.imf.orgឬ www.worldbank.org។

ចំណាយថវិកា និងមិនធ្វើឲ្យប៉ះពាល់ដល់ថវិកានៃវិស័យផ្សេងទៀតនៃសេដ្ឋកិច្ច និង គុណភាពនៃសេវាសាធារណៈ ពោលគឺ សុខាភិបាល អប់រំ និងកសិកម្មជាដើម។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាកើតឡើងនៅពេលដែលសេដ្ឋកិច្ចមិនរកបានរូបិយប័ណ្ណបរទេសគ្រប់គ្រាន់សម្រាប់ការសងបំណុលនៅក្នុងរយៈពេលវែងសមស្របមួយ ឬ នៅពេលដែលបំណុលកើនឡើងយ៉ាងលឿនខុសពីធម្មតា។ ប្រការនេះអាចកើតឡើងដោយសារមូលហេតុពីរ។ ទីមួយ ការបរាជ័យខាងគោលនយោបាយ[11]កើតឡើងក្នុងទម្រង់ជាច្រើន ដូចជាការរើសអើងប្រឆាំងនឹងវិស័យកសិកម្ម ដែលកាត់បន្ថយឬមិនជួយជំរុញទិន្នផលសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងសម្រាប់ការនាំចេញ គោលនយោបាយជំនួសការនាំចូលមិនមានប្រសិទ្ធភាព កម្រិតអត្រាការប្រាក់ដែលមិនលើកទឹកចិត្តដល់ការសន្សំនិងជំរុញឲ្យមានការវិនិយោគខ្ជះខ្ជាយ(វិនិយោគមិនមានផលិតភាពដល់សេដ្ឋកិច្ច) កំណើនផ្គត់ផ្គង់រូបិយវត្ថុលើសដែលបណ្តាលឲ្យមានអតិផរណា ភាពបរាជ័យក្នុងការវិនិយោគឲ្យបានគ្រប់គ្រាន់ក្នុងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងស្ថាប័នដែលមានប្រសិទ្ធិភាព ការគ្រប់គ្រងថ្លៃទំនិញនិងសេវាក្នុងទ្រង់ទ្រាយធំ និងការចំណាយលើផ្នែកយោធាដែលខ្ជះខ្ជាយ។ ពេលណាស្ថានភាពសេដ្ឋកិច្ចមានលក្ខណៈកាន់តែលំបាកឡើង នោះរដ្ឋាភិបាលនិងសហគ្រាសឯកជនកាន់តែច្រើនឡើងព្យាយាមខ្ចីបុលពីបរទេស។ ទីពីរ ការគំរាមកំហែងពីបរិយាកាសខាងក្រៅ[12] និងការគំរាមកំហែងដែលពាក់ព័ន្ធនឹងគោលនយោបាយក្នុងស្រុកមិនសូវល្អ ហើយការគំរាមកំហែងពីបរិយាកាសខាងក្រៅដែលកើតឡើងពីខាងក្រៅប្រទេសអាចជម្រុញឲ្យមានវិបត្តិមួយបាន។ ការគំរាមកំហែងទាំងនោះ រួមមាន៖ បម្រែបម្រួលអាកាសធាតុ សម្ពាធអតិផរណា ការធ្លាក់ចុះនៅក្នុង ការនាំចេញដោយសារគោលនយោបាយគាំពារនិយមនៅក្នុងប្រទេសឧស្សាហកម្ម និង ហេតុការណ៍កើតឡើងផ្ទួនគ្នាពីរ ដូចជាជម្ងឺហូឡង់[13]។ ជម្ងឺហូឡង់ត្រូវគេស្គាល់ថាជាការកើនឡើងមួយនៅក្នុងទាមទារសុំឲ្យមានប្រាក់បៀវត្សរ៍ខ្ពស់នៅក្នុងវិស័យផ្សេងទៀតដោយសារការរកឃើញធនធានប្រេងនិងឧស្ម័នធម្មជាតិ និងការផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់នៅក្នុងវិស័យនេះដែលបណ្តាលធ្វើឲ្យមានតម្លៃនាំចេញខ្ពស់ និងឧត្តមភាពប្រៀបធៀបទាបចំពោះទំនិញដែលបានផលិតក្នុងស្រុក និងការធ្លាក់ចុះសេដ្ឋកិច្ចនៅក្នុងទីផ្សារចំបងនានាសម្រាប់ការនាំចេញទាំងនោះ។

---

[11]ដូចបានសង្កេតឃើញនៅក្នុងមូលដ្ឋានទិន្នន័យ ODA ប្រាក់កម្ចីសម្បទានចំពោះប្រទេសកម្ពុជាភាគច្រើនគឺមានលក្ខណៈចម្រុះដោយផ្តោតលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (គម្រោងធារាសាស្ត្រ ផ្លូវថ្នល់ និង ស្ពាន) ដែលសំដៅជម្រុញផលិតកម្មកសិកម្ម និងការដឹកជញ្ជូនកាន់តែប្រសើរឡើង។ ប៉ុន្តែ ចាប់តាំងពីពេលចាប់ផ្តើមការឈ្លានពានរបស់ថៃ ចូលមកក្នុងតំបន់ជុំវិញប្រាសាទព្រះវិហារក្នុងឆ្នាំ២០០៨ ចំណាយយោធាក្នុងទម្រង់ជាចំណាយចរន្តបានកើនឡើងយ៉ាងលឿនតាំងពីឆ្នាំ២០០៩ ហើយប្រការនេះអាចបានធ្វើឲ្យមានភាពខ្សត់នៃថវិកាសម្រាប់ទ្រទ្រង់វិស័យអាទិភាពផ្សេងទៀត ពោលគឺ កសិកម្ម (សូមមើលការវិភាគច្បាប់ថវិកាឆ្នាំ២០១០ និង ២០១១ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជានៅក្នុងគេហទំព័រ www.ngoforum.org.kh ឬ www.cambodianbudget.org)។

[12] នៅក្នុងអំឡុងពេលនៃផលប៉ះពាល់វិបត្តិសេដ្ឋកិច្ចពិភពលោកលើប្រទេសកម្ពុជា កំណើនកសិកម្មត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលថាជាកត្តាមួយដែលបានជួយកាត់បន្ថយនិងសម្រាលភាពធ្ងន់ធ្ងរនៃផលប៉ះពាល់លើសេដ្ឋកិច្ច កម្ពុជាជាពិសេសក្រុមប្រជាជនក្រីក្រនិងងាយរងគ្រោះ។

[13] សូមមើលការពន្យល់លម្អិតអំពីជម្ងឺហូឡង់នៅក្នុង Macartan et al (ឆ្នាំ ២០០៧)។ គេចពីបណ្តាសារធនធាន។ ឯកសារចងក្រង។

វិបត្តិបំណុលគឺជាការចង្អុលប្រាប់នូវវិបត្តិសេដ្ឋកិច្ចរួមមួយនៅពេលដែលសេដ្ឋកិច្ចមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបង្កើតទំនុកចិត្តលើការសងបំណុលជាបន្ត។ ទំហំនៃបំណុលមិនសំខាន់ទេ ប៉ុន្តែគឺផលិតភាពនៃមូលធន(ប្រៀបធៀបទៅនឹងអត្រាការប្រាក់) និង កំណើននៃសេដ្ឋកិច្ចនេះហើយដែលសំខាន់ )ឬផលដែលបានមកពីការវិនិយោគដោយប្រើប្រាស់ប្រាក់កម្ចីដែលខ្ចីពីប្រភពខាងក្រៅ(។ ប្រសិនបើសេដ្ឋកិច្ចកំពុងលូតលាស់យ៉ាងលឿនគ្រប់គ្រាន់ និងក្នុងទិសដៅដែលត្រឹមត្រូវ នោះសេដ្ឋកិច្ចអាចដោះស្រាយនូវបំណុលកើនឡើងបាន។ អ្វីដែលសំខាន់នោះ គឺលទ្ធភាពរបស់សេដ្ឋកិច្ចក្នុងការសងបំណុល (ការប្រាក់និងប្រាក់ដើមនៃបំណុល) ដែលមានន័យថា សេដ្ឋកិច្ចត្រូវតែលូតលាស់ឡើងតាមវិធីមួយដែលអាចរកបានរូបិយប័ណ្ណបរទេសគ្រប់គ្រាន់(និងចំណូលពន្ធក្នុងករណីនៃបំណុលរដ្ឋាភិបាល)ដើម្បីសងម្ចាស់បំណុលបរទេស។ ប្រសិនបើសេដ្ឋកិច្ចដំណើរការបានសមស្រប គេអាចខ្ចីបុលបន្ថែមសម្រាប់សងបំណុលចាស់។ ប្រសិន បើបំណុលកើនឡើងលឿនជាងផស នោះមានសញ្ញាថាសេដ្ឋកិច្ចកំពុង.ស.រ៉ាប់រងនូវបន្ទុកបំណុល ទោះបីជាមានចន្លោះពេលមួយដែលនៅក្នុងនោះ ប្រការនេះអាចមិនមែនជាបញ្ហាក៏ដោយ។ ខណៈដែលបំណុលកើនឡើងចំណែកដ៏ធំមួយនៃធនធានសេដ្ឋកិច្ច និងចំណែកដ៏ធំមួយនៃថវិការបស់រដ្ឋាភិបាលនឹងត្រូវប្រើសម្រាប់តែសងបំណុល ដោយគ្មានការធានាថាកម្ចីត្រូវបានប្រើយ៉ាងមានប្រយោជន៍ឡើយ។ នៅពេលដែលមួយផ្នែកធំឬកំណើនមួយផ្នែកនៃបំណុលរបស់រដ្ឋាភិបាល បានមកពីប្រភពនៅក្រៅប្រទេស និង គិតជារូបិយប័ណ្ណបរទេស ការរំកិលបំណុលច្រើនតែពឹងផ្អែកលើបរទេស ហើយការសងការប្រាក់ត្រូវបង់ឲ្យបរទេសផងដែរ។ នៅពេលដែលស្ថានភាពរបស់រដ្ឋាភិបាល(ដូចជាការវាយតំលៃស្ថាប័ននិងគោលនយោបាយដោយធនាគារពិភពលោក) មិនត្រូវបានគេមើលឃើញថាមិនស្ថិតនៅក្នុងកំរិតល្អ នោះរដ្ឋាភិបាល នោះកំពុងជួបនឹងបញ្ហាបំណុលហើយ។ ប្រទេសដែលមានសំពាធបំណុលខ្ពស់ ឬជំពាក់បំណុលលើសលុប អាចស្វែងរកការអត់ឱនបំណុលពីក្រុមប្រទេសក្រុងប៉ារីស (Paris Club( ដែលជាម្ចាស់បំណុល និងម្ចាស់បំណុលពហុភាគី ដែលស្ថិតនៅក្រោមគំនិតផ្តួចផ្តើមសម្រាប់ប្រទេសក្រីក្រដែលជាប់បំណុលខ្ពស់ (HIPC) និងគំនិតផ្តួចផ្តើមការអនុគ្រោះបំណុលពហុភាគី(MDRI)[14]។

## បញ្ហានៅក្នុងការគ្រប់គ្រងបំណុលនិងហានិភ័យអនាគតរបស់ប្រទេសកម្ពុជា

ជារួម ព្រឹត្តិប័ត្រព័ត៌មាន ស្តីពីលក្ខខណ្ឌជំនួយនៃកម្ចីសម្បទានបរទេសសម្រាប់ប្រទេសកម្ពុជាបានគូសបង្ហាញថា៣៤%នៃគម្រោងកម្ចីសម្បទានចំនួន១០៤ដែលបានយកចេញពីមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ក្នុងខែ មិថុនា និង កក្កដា ឆ្នាំ២០១០ មិនទាន់មានព័ត៌មានគ្រប់គ្រាន់ស្តីពីលក្ខខណ្ឌនៃជំនួយ រួមមានអត្រាការប្រាក់ រយៈពេលអនុគ្រោះ និង រយៈពេលសង។ លើសពីនេះទៀត រាជរដ្ឋាភិបាលផលិតរបាយការណ៍ប្រចាំខែ ត្រីមាស និង ឆ្នាំស្តីពីការគ្រប់គ្រងបំណុល ប៉ុន្តែ របាយការណ៍នេះមិនត្រូវបានផ្សព្វផ្សាយសម្រាប់ការតាមដានជាសាធារណៈនៅឡើយ។ ព័ត៌មានក្រៅពីលក្ខខណ្ឌជំនួយដែលបានបង្ហាញជូនក្នុងអត្ថបទនេះ និង ព័ត៌មានស្តីពីការសម្រេចចិត្តស្តីពីបំណុលបរទេសមិនត្រូវបានដឹងគ្រប់ជ្រុងជ្រោយ

[14] សម្រាប់ព័ត៌មានលំអិតស្តីពីHIPC and MDRIសូមចូលទៅកាន់វែបសាយរបស់IMF តាមរយៈ www.imf.org

ដោយប្រជាពលរដ្ឋកម្ពុជាទេ[15]។ ការស្រាវជ្រាវបន្ថែមទៀត អាចត្រូវបានធ្វើដើម្បីស្វែងយល់ថាតើយើងកំពុងខ្ចីបុលឬកម្ចីពីប្រភពណា តើប្រភពប្រាក់កម្ចីណាខ្លះគឺជាប្រភពល្អជាងគេ ឬ តើត្រូវជ្រើសរើសម្ចាស់បំណុលយ៉ាងដូចម្តេចឲ្យមានលក្ខណៈតុល្យភាពនិងចីរភាព តើបំណុលឬបន្ទុកបំណុលបច្ចុប្បន្ននឹងមានថ្លៃចំណាយប៉ុន្មាន ចំពោះអ្នកបង់ពន្ធនិងសេវាសាធារណៈរបស់កម្ពុជា តើប្រាក់កម្ចីទាំងនោះត្រូវបានប្រើឬនឹងត្រូវបានប្រើនៅកន្លែងណាខ្លះ និង តើប្រាក់កម្ចីទាំងនោះត្រូវបានប្រើប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលឬទេ និង តើមានកត្តាអ្វីខ្លះដែលធានាការសម្រេចបានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលនូវប្រាក់កម្ចីទាំងនេះ។

ជាសន្និដ្ឋាន ថ្វីបើបំណុលបរទេស របស់កម្ពុជា និងកម្រិតកំណត់នៃបំណុលបានបង្ហាញហានិភ័យសម្ពាធបំណុលកម្រិតមធ្យមក្តី ក៏គេឃើញមានសញ្ញានៃកំណើនខ្ពស់នៅក្នុងបំណុលបរទេសចាប់តាំងពីឆ្នាំ ២០១១ដែរ (ពោលគឺការកើនឡើងកម្រិតអតិបរមាស្របច្បាប់សម្រាប់ការខ្ចីបុលថ្មីក្នុងច្បាប់ថវិកាឆ្នាំ២០១១ និងម្ចាស់ជំនួយថ្មី ដូចជាប្រទេសចិនជាដើម ជាមួយលក្ខខណ្ឌជំនួយសម្បទានមិនសូវមានអំណោយផលជាងគេ)។ ចំណុចទាំងនេះ អាចរុញច្រានប្រទេសកម្ពុជាឲ្យប្រឈមនឹងកម្រិតកាន់តែខ្ពស់នៃហានិភ័យនៃសម្ពាធបំណុល ដែលគឺជាកម្រិតកំណត់ដែលត្រូវវាយតម្លៃដោយធនាគារពិភពលោកនៅពេលក្រោយ។ ថ្វីបើការវាយតម្លៃបានបង្ហាញថាប្រទេសកម្ពុជាស្ថិតនៅក្នុងហានិភ័យកម្រិតមធ្យមនៃការប្រឈមនឹងសម្ពាធឬវិបត្តិបំណុលក្តី គោលនយោបាយនិងការអនុវត្តការងារនៃស្ថាប័នរបស់កម្ពុជាត្រូវបានចាត់ថ្នាក់ជាអ្នកអនុវត្តទន់ខ្សោយ បើយោងតាមការវាស់វែងដោយ CPIA របស់ធនាគារពិភពលោក ។ ប្រការនេះធ្វើឲ្យមានការបារម្ភថាប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពទ្វេទិសមួយដែលទាមទារឲ្យមានការកែលម្អការអនុវត្តការងារនៃស្ថាប័នរបស់ខ្លួន ទន្ទឹមគ្នានឹងសញ្ញានៃកំណើនបំណុលបរទេស បើមិនដូច្នោះទេ កម្ពុជានឹងប្រឈមមុខនឹងកម្រិតកាន់តែខ្ពស់នៃសម្ពាធបំណុល ដោយពិចារណាទៅលើកម្រិតចំណូលថវិកាជាតិដែលនៅមានកម្រិតទាបគិតជាភាគរយនៃផ.ស.ស។

មានចំនុចមួយចំនួនដែលត្រូវបានស្នើឡើងដោយការវិភាគរួមនៃធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ )IMF (លើនិរន្តរភាពបំណុល(DSA)ឆ្នាំ២០០៩ ចំពោះរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ពិចារណាក្នុងការជៀសវាងនូវវិបត្តិឬសម្ពាធបំណុលនាពេលអនាគត។ ទីមួយ កម្ពុជាគប្បីធានាឲ្យបាននិងធ្វើឲ្យមានតុល្យភាពនូវសម្បទានសមស្របពីម្ចាស់បំណុល ឬ អ្នកឲ្យខ្ចីបុលថ្មី (ដូចជា ប្រទេសចិន និង កូរ៉េខាងត្បូង ) និង ការកើនឡើងនូវវត្តមានរបស់ទាំងនេះនៅក្នុងប្រទេសកម្ពុជា ដោយសារតម្រូវការរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង សមត្ថភាពដើម្បីសងបំណុលថ្មី។ ទីពីរ ការវិភាគ DSA ឆ្នាំ ២០០៩ក៏បង្ហាញផងដែរនូវភាពចាំបាច់សម្រាប់អាជ្ញាធរក្នុងការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងបំណុល និងធានាឲ្យបានថាបំណុលថ្មីត្រូវបានចុះកិច្ចសន្យាលើមូលដ្ឋានមួយដែលមានចីរភាព។ ដោយសារកម្រិតអនុបាតបំណុល

[15] ចំណុចនេះគឺដោយសារប្រការដែលថាពលរដ្ឋឬអ្នកបង់ពន្ធកម្ពុជា នឹងត្រូវរ៉ាប់រងថ្លៃចំណាយទាក់ទិននឹងការសងបំណុលសាធារណៈពីក្រៅប្រទេស។

ធៀបទៅនឹង ចំណូលឡើងដល់កម្រិតកំណត់ និង ដូចដែលត្រូវបានគូសបញ្ជាក់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)[16] ប្រទេសកម្ពុជាគប្បីបង្កើនកិច្ចប្រឹងប្រែងបន្ថែមទៀតដើម្បីកែលម្អការប្រមូលចំណូល (ជាពិសេស ពន្ធ) ដើម្បីអាចឈានដល់អត្រាចំណូលអប្បបរមាគិតជាភាគរយនៃផ.ស.ស ដែលត្រូវបានស្នើឡើងក្នុងកម្រិត១៨%សម្រាប់បណ្តាប្រទេសអាស៊ីអគ្នេយ៍។ ទីបី ព័ត៌មានស្តីពីបំណុល ឬ របាយការណ៍ស្តីពីការគ្រប់គ្រងបំណុលគប្បីត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលនឹងអនុញ្ញាតឲ្យសាធារណៈជនកាន់តែច្រើនបានពិភាក្សាអំពីបញ្ហានៃការគ្រប់គ្រងបំណុលនិងតម្លាភាពបំណុល។ ប្រការនេះ ក៏នឹងជួយធានាឲ្យកាន់តែប្រាកដថែមទៀតនូវការរៀបចំបែងចែកនិងប្រើប្រាស់ប្រាក់កម្ចីឲ្យបានសមស្របទៅលើវិស័យដែលចាំបាច់បំផុតដែលផ្តល់ផលត្រឡប់ពីការវិនិយោគ និងដែលជំរុញកំណើនសេដ្ឋកិច្ចដែលមានចិរភាព។ លើសពីនេះទៀត ដោយមានព័ត៌មាននៅក្នុងដៃ ស្ថាប័នត្រួតពិនិត្យ ពោលគឺរដ្ឋសភា ក៏អាចបង្កើនការតាមដាននិងត្រួតពិនិត្យលើបំណុលបរទេសឲ្យកាន់តែប្រសើរឡើងថែមទៀតផងដែរ តាមរយៈការទាមទារឲ្យមានការកំណត់កាន់តែលម្អិតបន្ថែមទៀតនូវនិយ័តកម្មកម្រិតកំណត់បំណុលដែលត្រូវបានតាក់តែងនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ និងច្បាប់កែតំរូវថវិកា ព្រមទាំងបង្កើន កញ្ចប់ថវិកាបន្ថែមទៀតសម្រាប់អាជ្ញាធរសវនកម្មជាតិក្នុងការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែទូលំទូលាយថែមទៀតជាពិសេសលើការប្រើប្រាស់បំណុលសាធារណៈ និងការផ្សព្វផ្សាយរបាយការណ៍សវនកម្មឲ្យបានទាន់ពេលវេលា។

## ឯកសារយោង:


1. Joint IMF/World Bank Debt Sustainability Analysis 2010. International Monetary Fund and International Development Association, Cambodia.
2. Joint IMF/World Bank Debt Sustainability Analysis 2009. International Monetary Fund and International Development Association, Cambodia.
3. Joint IMF/World Bank Debt Sustainability Analysis 2006. International Monetary Fund and International Development Association, Cambodia.
4. 2009 IDA Resource Allocation Index (IRAI). World Bank Country Policy and Institutional Assessments (2009).
5. Aart Kraay and Vikram Nehru (2006). When is external debt sustainable?. World Bank Economic Review.
6. IMF/World Bank (2006). How to do debt sustainability analysis for low-income countries?
7. Peter Hess and Clark Ross (1997). Economic Development: Theories, Evidence and Policies. The Dryden Press, Harcourt Brace College Publishers.
8. Stuart R. Lynn (2003). Economic Development: Theory and Practice for a Divided World. Prentice Hall Publisher.
9. Malcolm et al, (1996). Economics of Development. 4th Edition. W.W. Norton & Company, New York and London.


[16] កម្រិត១៨% នេះត្រូវបានគូសបញ្ជាក់ដោយលោក John Nelmes អតីតតំណាងប្រចាំប្រទេសនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)នៅក្នុងបទបង្ហាញរបស់លោកនៅក្នុងសន្និសីទស្តីពីប្រមើមើលសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ ដែលត្រូវបានរៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដោយសហការជាមួយធនាគារ ANZ Royal Bank នៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ។

10. Sing C. Chew and Robert A Denemark (1996). The Underdevelopment of Development. Edited. Sage Publication, California, USA.
11. Arturo Escobar (1995). Encountering Development: the Making and Unmaking of the third world. Princeton University Press, Princeton, New Jersey, UK.
12. N. Gregory Mankiw (2003). Macroeconomics. 5th Edition. Harvard University, Worth Publishers.
13. Joseph E. Stiglitz (2001), edited. Frontiers of Development Economics: the Future in Perspective. World Bank, Washington, USA, Oxford University Press.
14. Subrata Ghatak (1995). Introduction to Economics. 3rd Edition. Routledge, London and New York.

## ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមទំនាក់ទំនង៖

លោក ជា គីមសុង ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉េលៈ ngoforum@ngoforum.org.kh
វេបសាយៈ www.ngoforum.org.kh
អាស័យដ្ឋានៈ ផ្ទះលេខ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទូលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

# ការគ្រប់គ្រងប្រទេសកម្ពុជា: ដំណាក់កាលខាងមុខនៃកំណើន

អ្វីដែលប្រទេសកម្ពុជាគិតនៅថ្ងៃនេះ មានឥទ្ធិពលលើទិសដៅដែលប្រទេសធ្វើនាពេលអនាគត។ នៅក្នុងស្ថានភាពមួយដែលមិនប្រាកដប្រជា និងការប្រកួតប្រជែងជាសកលការធ្វើផែនការ និងការបង្កើតកម្មវិធីនយោបាយសម្រាប់កំណើនប្រកបដោយចីរភាព និងមានមូលដ្ឋានទូលំទូលាយជាង គឺ មានសារៈសំខាន់ និងទាន់ពេលវេលា។ ជាមួយប្រជាពលរដ្ឋពេញវ័យ និងពោរពេញទៅដោយក្តីសង្ឃឹមកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមប្រហែល៨% នៅក្នុងមួយទសវត្សរ៍កន្លងមក គប្បីផ្តល់ឲ្យយើងនូវទំនុកចិត្តក្នុងការរៀបចំនូវ ផែនការទាំងនេះ ក៏ដូចជាការគិតគូរឲ្យកាន់តែទូលំទូលាយ។

ថ្វីបើវិស័យកសិកម្មនិងទេសចរណ៍នឹងបន្តដើរតួនាទីសំខាន់នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជានៅក្នុងបណ្តាទសវត្សរ៍ខាងមុខក្តី អត្ថបទនេះផ្តោតលើឧស្សាហូបនីយកម្មផ្អែកលើកសិកម្មដែលគប្បីគឺជាគន្លឹះមួយទៀតសម្រាប់អភិវឌ្ឍប្រកបដោយប្រសិទ្ធផលនូវសេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅកាន់មាគ៌ាកំណើនកាន់តែខ្ពស់។ ការប្រែក្លាយឲ្យទៅជាការពិតជាក់ស្តែង និងជោគជ័យនៃឧស្សាហូបនីយកម្មប្រភេទនេះនឹងមិនត្រឹមតែបង្កើនសមត្ថភាពផលិតរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងលើកកម្ពស់ឥទ្ធិពលបណ្តាញនិងសហការនៅក្នុងចំណោមវិស័យស្នូលមានស្រាប់ថែមទៀតផង។ ទីមួយ វានឹងជួយបង្កើតតម្លៃបន្ថែមសម្រាប់ទិន្នផលកសិកម្មតាមរយៈ "ការផ្សារភ្ជាប់ការប្រែក្លាយពីការនាំចេញនូវផលិតផលកសិកម្មមិនទាន់កែច្នៃទៅជាការនាំចេញផលិតផលកសិកម្មដែលមានការកែច្នៃវិញ"[17]។ ទីពីរ វានឹងជួយរក្សាមួយផ្នែកធំនៃខ្សែសង្វាក់ផលិតកម្ម នៅក្នុងឧស្សាហកម្មស្នូល តាមរយៈ "ការបង្កើតទំនាក់ទំនងនៅក្នុងវិស័យនានា[18]"ដោយផ្តត់ផ្គង់ធាតុចូលក្នុងស្រុកថែមទៀតសម្រាប់វិស័យដទៃទៀត ពោលគឺការផ្គត់ផ្គង់កប្បាសទៅឲ្យឧស្សាហកម្មកាត់ដេរ ដែលនៅពេលនេះ គឺមានត្រឹមតែកាត់តម្រឹមនិងកាត់ និង អាហារកែច្នៃសម្រាប់វិស័យទេសចរណ៍តែប៉ុណ្ណោះ។ ទីបី ដោយផ្សារភ្ជាប់ឧស្សាហកម្មស្នូលមានស្រាប់ តាមរយៈការផ្គត់ផ្គង់ ខ្សែសង្វាក់ផលិតកម្មនិងតម្រូវការច្រើន ឧស្សាហូបនីយកម្មដែលមានលក្ខណៈផ្អែកលើធនធាននិងប្រើកំលាំងពលកម្មច្រើននេះនឹងដើរតួនាទីយ៉ាងសំខាន់មួយក្នុងការបោះជំហានទៅកាន់ឧស្សាហូបនីយកម្មមួយដែលផ្អែកលើបច្ចេកវិទ្យាទំនើបជាង។ ជារួម កសិ-ឧស្សាហូបនីយកម្ម និង វិស័យស្នូល (កសិកម្ម ទេសចរណ៍ និង កាត់ដេរ) មុខជាងពង្រឹងគ្នាទៅវិញទៅមក និងបង្កើនសមត្ថភាពផលិតនៅតាមវិស័យនានានៃសេដ្ឋកិច្ចកម្ពុជា។

ដើម្បីសម្រេចបានគោលដៅនេះ ប្រទេសកម្ពុជាចាំបាច់ត្រូវដោះស្រាយឲ្យបាននូវភាពមានកំរិតខាងសមត្ថភាពទាំងឡាយ រួមមានតាំងពីហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា មូលធន ជំនាញ គ្រប់គ្រង រហូតដល់

---

[17]កំណត់សម្គាល់របស់អ្នកបកប្រែ: ការផ្សារភ្ជាប់ទៅក្រោយគឺជាពាក្យបច្ចេកទេសសេដ្ឋកិច្ចមួយ ដែលមានន័យថាជាអនុក្រមចែកចាយដែលផ្សារភ្ជាប់អ្នកផលិតឬអ្នកផ្គត់ផ្គង់ជាមួយអតិថិជន។

[18]កំណត់សម្គាល់របស់អ្នកបកប្រែ: ការផ្សារភ្ជាប់ទៅក្រោយគឺជាពាក្យបច្ចេកទេសសេដ្ឋកិច្ចមួយ ដែលមានន័យថាជាច្រកដែលព័ត៌មាន វត្ថុធាតុ និង ប្រាក់ហូរវវាងក្រុមហ៊ុននិងអ្នកផ្គត់ផ្គង់របស់ខ្លួន និង បង្កើតបណ្តាញមួយនៃការពឹងគ្នាទៅវិញទៅមកខាងសេដ្ឋកិច្ច។

ក្របខ័ណ្ឌស្ថាប័ន។ កិច្ចការជាច្រើនត្រូវបានសម្រេចរួចហើយ ទោះបីជាយ៉ាងក៏ដោយ នៅមានកិច្ចការច្រើនទៀតដែលត្រូវកែលម្អ។ នៅត្រង់នេះ គោលនយោបាយចំពោះសហគ្រាសធុនតូចនិងមធ្យម និងថ្លៃថាមពល និង តួនាទីរបស់រដ្ឋ គួរត្រូវពិចារណាបន្ថែម ដោយសារកត្តាទាំងបីនេះ នឹងជួយជម្រុញ ល្បឿននៃសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងកិច្ចដំណើរការនៃឧស្សាហូបនីយកម្ម។

ដោយសារភាគច្រើននៃសហគ្រាសធុនតូចនិងមធ្យមកម្ពុជាមានលក្ខណៈក្រៅប្រព័ន្ធ និងត្រូវបានគ្រប់គ្រងមិនបានល្អ ពួកគេមិនមានលទ្ធភាព គ្រប់គ្រាន់ក្នុងការទទួលបានការជួយគាំទ្រឥណទានក្នុងតម្លៃសមស្របនិងបច្ចេកវិទ្យាល្អឡើយ។ ទោះបីជាពួកគេមានលទ្ធភាពក្ដី ក៏វាមុខជាមានថ្លៃចំណាយខ្ពស់ដែរ។ ក្នុងន័យនេះ បញ្ហាប្រឈមគឺការនាំពួកគេឲ្យចូលមកក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលនៅក្នុងនោះ សហគ្រាសធុនតូចនិងមធ្យមអាចមានលទ្ធភាពប្រសើរជាងក្នុងការទាក់ទាញ វិនិយោគិន/ឥណទាយក ល្អៗ ដែលជាលទ្ធផលនៃបទដ្ឋាន/របាយការណ៍គណនេយ្យ និងរចនាសម្ព័ន្ធគ្រប់គ្រងដោយមានលក្ខណៈកាន់តែអាចទុកចិត្តបាន។ គោលនយោបាយសារពើពន្ធនឹងជាបញ្ហាចម្បងមួយនៅក្នុងបញ្ហាប្រឈមនេះ។គោលនយោបាយសារពើពន្ធលើប្រាក់ចំណេញបច្ចុប្បន្ន មិនបានលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម យ៉ាងហោចណាស់តាមវិធីពីរៈ ត្រូវចុះបញ្ជីផ្លូវការ និ ត្រូវប្រកួតប្រជែងជាមួយក្រុមហ៊ុនបរទេសដែលទទួលបានការរួចពន្ធក្នុងអំឡុងពេល (៣-៦ ឆ្នាំ )។ អត្រាពន្ធលើប្រាក់ចំណេញបច្ចុប្បន្ន (តាមកំរិតបទដ្ឋាន ២ ០%) គប្បីទាបជាងនេះច្រើន (២-៥%) ឬ ប្រសើរជាងនេះទៅទៀត សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកគប្បីទទួលបានការរួចពន្ធដូចក្រុមហ៊ុនបរទេសដែរ។ ក្រៅពីនេះ ឥណទានពន្ធសហគ្រាសធុនតូចនិងមធ្យមដែលនៅក្នុងនោះ ប្រាក់ចំណេញមិនត្រូវបានគិតពន្ធ ប្រសិនបើវាត្រូវគេយកទៅវិនិយោគសម្រាប់ធ្វើឲ្យប្រសើរឡើងឬពង្រីកក្រុមហ៊ុនក៏គប្បីត្រូវបានអនុវត្តផងដែរ។ គោលនយោបាយសារពើពន្ធដែលបានស្នើឡើងនេះ នឹងមិនត្រឹមតែនាំឲ្យសហគ្រាសធុនតូច និងមធ្យមរបស់យើងចូលមកក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យពួកគេប្រកួតប្រជែងប្រកបដោយយុត្តិធម៌ផងដែរជាមួយក្រុមហ៊ុនបរទេស និងផលិតផលនាំចូល។

តម្លៃថាមពលខ្ពស់គឺជាឧបសគ្គសម្រាប់ការចូលនិងការជំរុញកំណើនរបស់សហគ្រាសធុនតូចនិងមធ្យម និងសម្រាប់ឲ្យក្រុមហ៊ុនបរទេសចូលមកវិនិយោគ។ កិច្ចពិភាក្សានានាត្រូវបានធ្វើឡើងស្តីពីពន្ធលើប្រេងសាំង ការឧបត្ថម្ភធន និងជម្រើសថាមពល។ ប៉ុន្តែ យើងចាំបាច់ត្រូវបន្ទាបតម្លៃថាមពលរបស់យើងយ៉ាងហោចណាស់ ឲ្យបានដល់កម្រិតមួយដែលស្មើនឹងតម្លៃប្រេងសាំងនៃប្រទេសសជិតខាងយើងដែរ ប្រសិនបើប្រទេសកម្ពុជាចង់ប្រកួតប្រជែងនិងធ្វើឧស្សាហូបនីយកម្ម។

តួនាទីរបស់រដ្ឋក្នុងការជួយសម្រួល គឺមានសារៈសំខាន់យ៉ាងខ្លាំង។ ឧទាហរណ៍ ក្រៅពីការជួយសម្របសម្រួលដោយផ្ទាល់ទៅលើសក្តានុពលទីផ្សារដែលមានឧត្តមភាពប្រៀបធៀបរបស់យើង រាជរដ្ឋាភិបាលអាចផ្តល់ការជួយគាំទ្រខាងស្ថាប័នជូនដល់ផ្នែកឯកជន ជាពិសេសសហគ្រាសធុនតូចនិងមធ្យម ក្នុងក្របខណ្ឌនៃការកសាងសមត្ថភាព ការជួយគាំទ្រខាងផ្នែកបច្ចេកវិទ្យា និងសេវាពិគ្រោះយោបល់។ ទោះបីជាយ៉ាងណាក៏ដោយ ការងាកចេញពីស្ថានភាពរដ្ឋបច្ចុប្បន្នទៅកាន់រដ្ឋសម្របសម្រួលមួយដែលមានលក្ខណៈ

ខ្លាំងក្លា តម្រូវឲ្យមានកិច្ចដំណើរការរយៈពេលវែងនិងឆន្ទៈនយោបាយមាំមួន។ ជំហានទីមួយ គប្បីឈាន ចេញពីស្ថានភាពរដ្ឋាភិបាលបច្ចុប្បន្នទៅកាន់រដ្ឋាភិបាលមួយដែលមានលក្ខណៈលើកទឹកចិត្តនិងមិនរារាំង។ មានតែនៅពេលដែលយើងមានការិយាលេខានុការ(bureaucrat) និងអ្នកបច្ចេកទេស (technocrat)មិនមាន និន្នាការនយោបាយនិងមានប្រសិទ្ធភាពប៉ុណ្ណោះ ទើបរាជរដ្ឋាភិបាលអាចធ្វើអន្តរាគមន៍និងជួយសម្រប សម្រួលបាន។ ជាការពិតណាស់អ្នក សម្របសម្រួលដែលមិនមានប្រសិទ្ធភាព ទោះបីមានបំណងល្អក្ដី អាច ធ្វើឲ្យមានផលអវិជ្ជមានច្រើនជាងផលវិជ្ជមាន។

ជារួម ឧស្សាហូបនីយកម្មផ្អែកលើកសិកម្មមានសក្ដានុពលនៅក្នុងដំណាក់កាលខាងមុខនៃកំណើន របស់កម្ពុជា និង ជាកិច្ចដំណើរការមួយនៃការកសាងសមត្ថភាពស្រូបយក សម្រាប់បច្ចេកវិទ្យាផលិតកម្មកាន់ តែជឿនលឿននៅក្នុងដំណាក់កាលបន្ទាប់។ ក្នុងនាមជាប្រទេសដែលបានចូលខ្លួនយឺតទៅក្នុងឧស្សាហូប នីយកម្មផ្អែកលើកសិកម្ម យើងមានឧត្ដមភាពច្រើននៅក្នុងដំណាក់កាលនៃខ្សែកោងរៀនសូត្រមិនមែន ខ្សែកោងប្រកួតប្រជែងឡើយ។ ហេតុដូចនេះហើយ យើងនឹងមិនត្រឹមតែ "រៀនដើម្បីប្រកួតប្រជែង" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង "ប្រកួតប្រជែងដើម្បីអភិវឌ្ឍ" និង ជាការពិតណាស់ "អភិវឌ្ឍដើម្បីប្រកួតប្រជែង" ទៀតផង។

ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងត្រូវបានរងគំនាបដោយប្រទេសមានសេដ្ឋកិច្ចលូតលាស់ធំពីរ និង ត្រូវ បានមើលរំលងដោយវិនិយោគិនបរទេសធំៗ និង ក្រុមហ៊ុនផលិតគ្រឿងកុំព្យូទ័រ ( blue-chip) ដោយសារ ផលិតភាពទាប ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងថ្លៃចំណាយក្រៅផ្លូវការខ្ពស់។ ប៉ុន្តែ នៅក្នុងប៉ុន្មាន ទសវត្សរ៍ខាងមុខនេះ នៅពេលណាដែលបញ្ហាប្រឈមទាំងនេះត្រូវបានដោះស្រាយ តើមានអ្នកណានឹង បដិសេធនូវលទ្ធភាពដែលថាប្រទេសកម្ពុជាដ៏មានស្ថេរភាពអាចគឺជាមូលដ្ឋានផលិតកម្មល្អមួយ ដោយសារ នៅកៀកនឹងទីផ្សារទាំងពីរនិងប្រព័ន្ធសេរីរបស់ខ្លួន?

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងក្នុងអត្ថបទនេះ សូមទំនាក់ទំនង៖

**ហេង ឌីណា**
**និស្សិត**
មហាវិទ្យាល័យក្រាហ្វដខាងសេដ្ឋកិច្ចនិងរដ្ឋាភិបាល (Crawford School of Economics and Government)
សាកលវិទ្យាល័យជាតិអូស្ត្រាលី (Australian National University)
**អ៊ីម៉ែល:** dynaheng@gmail.com